01154027



ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Oct-2015, 13:30
CMS/CFO: Sann Rada

# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅសំណើសុំកិច្ចស៊ើបសួរនៅលើព្រឹត្តិការណ៍ដែលបានពិពណ៌នាក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ សំ សិទ្ធី

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

លីវ សុវណ្ណា

Doreen CHEN

Xiaoyang NIE

Marina HAKKOU

**ផ្ញើជូន៖**

**សហមេធាវី ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**PICH Ang**

Marie GUIRAUD

## I. សេចក្ដីផ្ដើម

១. នៅថ្ងៃទី៧ ខែ កញ្ញា ឆ្នាំ ២០១៥ សហមេធាវីការពារក្ដី នួន ជា (“ក្រុមមេធាវីការពារក្ដី”) បានដាក់សំណើមួយ ស្នើសុំអង្គជំនុំជម្រះនេះតែងតាំងអ្នកស៊ើបអង្កេតម្នាក់សម្រាប់គោលបំណងវាយតម្លៃភាពជឿជាក់បាននូវសក្ខីកម្មរបស់ សំ សិទ្ធី ដែលបានផ្ដល់នៅចំពោះមុខអង្គជំនុំជម្រះនេះកាលពីថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៥ (“សំណើ”)[1]។ សំណើនេះបញ្ជាក់សារជាថ្មីនូវអំណះអំណាងជាច្រើន ដែលបានលើកនៅក្នុងបណ្ដឹងសាទុក្ខរបស់ នួន ជា[2] ប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១[3] រួមទាំងអំណះអំណាងដែលថា សិទ្ធិរបស់ នួន ជា ដើម្បីស៊ើបអង្កេតបទចោទប្រកាន់ និងសួរដេញដោលភស្តុតាងប្រឆាំងនឹងគាត់ ត្រូវបានរំលោភជាប្រព័ន្ធក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២[4] ហើយថាសក្ខីកម្មរបស់ សំ សិទ្ធី ជាភស្តុតាងសំខាន់នៅក្នុងសាលក្រម ដោយសារជាសក្ខីកម្មតែមួយគត់នៅក្នុងសំណុំរឿង ដែលពិពណ៌នាពីការសម្លាប់ទាហានសាធារណរដ្ឋខ្មែរ ដែលត្រូវបានចាប់ខ្លួននៅពេលជម្លៀសចេញពីទីក្រុងនៅខែ មេសា ឆ្នាំ១៩៧៥[5]។ សំណើនេះផ្ដល់អំណះអំណាងបន្ថែមទៀតថាសក្ខីកម្មរបស់ សំ សិទ្ធី នៅចំពោះអង្គជំនុំជម្រះនេះខ្វះចំណុចសំខាន់ៗជាច្រើន ដូចជាកំហុស និងភាពមិនស៊ីសង្វាក់គ្នា និងមិនត្រូវបានបញ្ជាក់ដោយឯកសារ ឬសាក្សីផ្សេងទៀត មិនថាឡើយភស្តុតាងកោសលវិច្ច័យណាមួយ[6]។ នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ ទាំង

---

[1] **F28** សំណើសុំកិច្ចស៊ើបសួរទៅលើព្រឹត្តិការណ៍នានាដែលបានពិពណ៌នាក្នុងក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្ម របស់ សំ សទ្ធី” កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ (“សំណើ”)។

[2] **F16** “បណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១” ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ (“បណ្ដឹងសារទុក្ខ”)។

[3] **E313** សាលក្រមនៅក្នុងសំណុំរឿង០០២/០១” ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ (“សាលក្រម”)។

[4] **F28** សំណើនៅកថាខណ្ឌ២៩, F16 បណ្ដឹងសាទុក្ខនៅកថាខណ្ឌ៣១-៣២, ១៣៣-១៦៥

[5] **F28** សំណើនៅកថាខណ្ឌ២៦-២៨, F16 បណ្ដឹងសាទុក្ខនៅកថាខណ្ឌ ៥៨១-៥៩៦

[6] **F28** សំណើនៅកថាខណ្ឌ៦-២៥។

សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតប[7]។ ហេតុដូច្នេះក្រុមមេធាវីការពារក្តីដាក់សារណាតបនេះ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា។

## II. អំណះអំណាង

### ក. សហព្រះរាជអាជ្ញាយល់ខុសពីគោលបំណងរបស់សំណើនេះ និង សារសំខាន់នៃសក្ខីកម្មរបស់ សំ សិទ្ធី

២. កម្លាំងរុញទូទៅនៃចម្លើយតបរបស់សហព្រះរាជអាជ្ញា គឺថាសំណើនេះជាកិច្ចប្រឹងប្រែងមួយធ្វើឡើងមិនទាន់ពេល និងដោយតម្លាភាព ដើម្បីជួសជុលការខូចខាតមកលើករណី នួន ជា ដែលបង្កឡើងដោយសក្ខីកម្មរបស់ សំ សិទ្ធី។ ពួកគេលើកអំណះអំណាងថា សំ សិទ្ធី គឺជាសាក្សីតែម្នាក់គត់ក្នុងចំណោមសាក្សីជាច្រើន ដែលបានពិពណ៌នាអំពីលំនាំនៃការកំណត់មុខសញ្ញាទាហាន និងមន្ត្រីសាធារណរដ្ឋខ្មែរ[8] ហើយថាសក្ខីកម្មរបស់គាត់ មិនផ្លាស់ប្តូរ និងអាចជឿទុកចិត្តបាន ហើយថាមិនចាំបាច់ទទួលបានភស្តុតាងបញ្ជាក់សម្រាប់សាក្សីនិមួយៗក្នុងចំណោមសាក្សីរាប់រយនាក់ដែលបានផ្តល់សក្ខីកម្មនៅក្នុងរឿងក្តីព្រហ្មទណ្ឌដ៏ស្មុគ្រស្មាញនេះទេ[9]គោលបំណងនៃចម្លើយតបទាំងនេះ មិនបានដោះស្រាយភាពជាក់លាក់នៃសក្ខីកម្មរបស់ សំ សិទ្ធី ឬសេចក្តីត្រូវការនូវភស្តុតាងបញ្ជាក់វាទេ។ គោលបំណងចម្លើយតបនេះ គឺដើម្បីបង្កើតរូបភាពក្រៅមិនពិតនៃការមិនអាចចៀសវាងបានអំពីភស្តុតាងលើកំណត់ហេតុ និងបំភ័យអង្គជំនុំជម្រះនេះក្នុងការព្រមទទួលយក តាមរយៈការបំផ្លើស។

---

[7] **F28/1** ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់ នួន ជា សុំកិច្ចស៊ើបសួរទៅលើព្រឹត្តិការណ៍នានាដែលបានពិពណ៌នាក្នុងក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ សំ សទ្ធី កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ (“ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី”) ។ **F28/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំកិច្ចស៊ើបសួរទៅលើព្រឹត្តិការណ៍នានាដែលបានពិពណ៌នាក្នុងក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ សំ សទ្ធី” កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ ២០១៥(“ចម្លើយតបរបស់សហព្រះរាជអាជ្ញា”) ។

[8] **F28/2** ចម្លើយរបស់របស់សហព្រះរាជអាជ្ញានៅកថាខណ្ឌ៣៧។

[9] **F28/2** ចម្លើយរបស់របស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ៣៥។

៣. សហព្រះរាជអាជ្ញាហាក់ដូចជាសន្មតថា គោលបំណងតែមួយនៃការស្តាប់សក្ខីកម្ម សំ សិទ្ធី លើបណ្តឹងសាទុក្ខ គឺដើម្បីពិនិត្យចំណុចចន្លោះប្រហោងនៅក្នុងការថតសំឡេងនៃការស្តាប់ចម្លើយរបស់គាត់។ តែបណ្តឹងសាទុក្ខ គឺផ្អែកលើការចោទប្រកាន់ទូលំទូលាយដែលថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសដដែលៗផ្នែកច្បាប់នៅក្នុងការវាយតំលៃរបស់ខ្លួននៃភស្តុតាងនៅក្នុងសាលក្រម រួមបញ្ចូលទាំងនៅក្នុងចំណោមបញ្ហាផ្សេងទៀត បទដ្ឋានដែលអង្គជំនុំជម្រះសាលាដំបូង បានអនុវត្តសម្រាប់ការទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយនៅក្រៅតុលាការផងដែរ[10] និងការប្រព្រឹត្តរបស់អង្គជំនុំជម្រះសាលាដំបូងលើតំលៃភវនីយភាពនៃកំណត់ហេតុស្តាប់ចម្លើយទាំងនេះនៅក្នុងសាលក្រម[11] និងការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង លើភាពជឿជាក់បាន និងភាពអាចទុកចិត្តបានរបស់សាក្សីនៅក្នុងសវនាការ[12]។ ការប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី គឺជាការបង្ហាញយ៉ាងមុតស្រួចនៃលំនាំនេះ បើពិនិត្យពីសារសំខាន់នៃសក្ខីកម្មរបស់គាត់នៅក្នុងបរិបទធំទូលាយនៃភស្តុតាង។ តាមពិតវាមិនធម្មតាទេដែលសក្ខីកម្មរបស់សាក្សីម្នាក់ដែលបានឃើញការសម្លាប់ ក្នុងកណ្តាលសមុទ្រនៃពាក្យចាមអារាម និងការនិយាយស្មានៗ ស្រាប់តែបានបាត់ស្រមោលភ្លាមពីខ្សែអាត់ថតសំលេងនោះ។ ប៉ុន្តែបញ្ហានៃភាពអាចទុកចិត្តបាននៃសក្ខីកម្មរបស់ សំ សិទ្ធី មិនចាប់ផ្តើម និងបញ្ចប់ជាមួយនឹងលទ្ធភាពដែលថា វាជាផលនៃការសមគំនិតទុច្ចរិតរបស់សហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ។ តាមពិតនេះគឺជាបទដ្ឋានទាបមួយ។ ការដាក់ឯកសារដោយក្រុមមេធាវីការពារក្តីក្នុងអំឡុងពេលការជំនុំជម្រះបានបង្ហាញថា ការថតសំលេងនៃការស្តាប់ចម្លើយសាក្សីជាច្រើនមានភាពមិនប្រក្រតីជាក់លាក់ជាច្រើន[13] តែបណ្តឹងសាទុក្ខមិនមានសេចក្តីសន្និដ្ឋានអំពីសាក្សីណាមួយក្នុងចំណោមសាក្សីទាំងនេះទេ។ ក្រុមមេធាវីការពារក្តីស្វែងរកការស្តាប់សក្ខីកម្មរបស់ សំ សិទ្ធី

---

[10] **F16,** បណ្តឹងសាទុក្ខនៅកថាខណ្ឌ១៥៤-១៦២។

[11] **F16,** បណ្តឹងសាទុក្ខនៅកថាខណ្ឌ១៦៣-១៦៥។

[12] **F16,** បណ្តឹងសាទុក្ខនៅកថាខណ្ឌ១៧២-២១១។

[13] **E142** សំណើសុំកិច្ចស៊ើបសួរតាមវិធាន៣៥ ទាក់ទងនឹងភាពមិនស៊ីសង្វាក់គ្នានៅក្នុងខ្សែរអាត់សំលេង និង កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស” ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១។

ដោយផ្តែកជាពិសេសលើកាលៈទេសៈទាំងមូល រួមទាំងឋានៈរបស់គាត់ ជាសាក្សីផ្ទាល់ភ្នែកតែម្នាក់គត់ចំពោះការសម្លាប់តាមការសន្មត ការគ្មានភស្តុតាងបញ្ជាក់ និង ភាពចន្លោះប្រហោងនៅក្នុងការថតសំលេងនៃការស្តាប់ចម្លើយ។ នៅឆ្ងាយពីការប្រឹងប្រែងដើម្បី "ចំណាត់ថ្នាក់ឡើងវិញ" នូវសក្ខីកម្មរបស់ សំ សិទ្ធី ឬ "ជាសះស្បើយ" ពីរបួស ឬ "ការរងរបួសដោយខ្លួនឯង" សំណើនេះធ្វើតាមដោយផ្ទាល់ពីបញ្ហាការវាយតំលៃភស្តុតាងដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសាលក្រម ដែលថាជំនួសឲ្យការដាក់ភស្តុតាងឲ្យក្រោមការត្រួតពិនិត្យដូចដែលផ្ទុះបញ្ចាំង និងតម្រូវដោយយុត្តិសាស្ត្រ[14] អង្គជំនុំជម្រះសាលាដំបូងបែរជា "លេបទាំងមូល"[15] នៃចំណិតតូចៗនៃភស្តុតាងដាក់បន្ទុក ហើយគ្រវែងចោលវត្ថុនីមួយៗដែលជាភស្តុតាងដោះបន្ទុកទៅវិញ។

៤. ជាទូទៅ វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញានៅក្នុងចម្លើយតបរបស់ពួកគេទៅនឹងបណ្តឹងសាទុក្ខ[16] សហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងអំណះអំណាងជាក់លាក់របស់យើងខ្ញុំអំពីសារសំខាន់នៃសក្ខីកម្មរបស់ សំ សិទ្ធី។ សហព្រះរាជអាជ្ញាសំអាងយុត្តិសាស្ត្រធម្មតាក្នុងគោលបំណងថា ភស្តុតាងបញ្ជាក់មិនមែនជាបុរេលក្ខខណ្ឌចំពោះភាពអាចទុកចិត្ត *ជាទូទៅ* ប៉ុន្តែមិនបានយោងទៅលើអំណះអំណាងរបស់យើងខ្ញុំដែលថា ភស្តុតាងបញ្ជាក់គឺសំខាន់ ដើម្បីគាំទ្រដល់សក្ខីកម្មរបស់សាក្សីនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថាការប្រើប្រាស់ភស្តុតាងរបស់ សំ សិទ្ធី ដោយអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងអត្ថិភាពនៃគោលនយោបាយពាក់ព័ន្ធនឹងសហឧក្រិដ្ឋរួម (JCE) គឺ "កម្រិត" និង"ស្តួចស្តើង" ប៉ុន្តែពេញចិត្តចំពោះការយោងជាទូទៅលើកថាខណ្ឌជាច្រើននៅក្នុងសាលក្រម ដែលពិភាក្សាលើបញ្ហានេះ[17]។ មិនមានភាគីណាមួយជំទាស់ថាសាក្សី សំ សិទ្ធី គឺជាសាក្សីសំខាន់តែមួយគត់ចំពោះការអនុវត្តមួយដែលសាល

---

[14] សូមមើលកថាខណ្ឌ ៨ ដល់ ៩ ខាងលើ ។

[15] **F16,** បណ្តឹងសាទុក្ខ នៅកថាខណ្ឌ៥៥៥។

[16] **F16,** ឥរិយាបថចំពោះបណ្តឹងសាទុក្ខ បញ្ចៀបចូលក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញា។ វាមិនងាយស្រួលដើម្បីបង្ហាញនៅក្នុងសារណាឆ្លើយតបទេ។

[17] **F28/1** ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅកថាខណ្ឌ៣៤-៣៥។

ក្រុមរកឃើញថា ជាការអនុវត្តទូទៅនៅទូទាំងប្រទេស ហើយបើគ្មានការផ្តន្ទាទោសសម្រាប់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅទួលពោធិ៍ជ្រៃទេ នោះនឹងមិនមានការសម្រេចឡើយ[18]។

៥. ទីបំផុតភាពជឿជាក់បាននៃសក្ខីកម្មរបស់ សំ សិទ្ធី គឺជាបញ្ហានៅស្ថិតក្នុងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះនេះ។ តែការអះអាងរបស់សហព្រះរាជអាជ្ញាដែលថាសក្ខីកម្មរបស់ សំ សិទ្ធី ជឿជាក់ "ជាទីបំផុត" គឺគ្មានអ្វីក្រៅពីគួរឲ្យអស់សំណើចនោះទេ។ អង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកលើភស្តុតាងរបស់ សំ សិទ្ធី ថាជាមូលដ្ឋានតែមួយគត់នៃការរកឃើញទាហានមួយក្រុម និងក្រុមគ្រួសាររបស់ពួកគេ ត្រូវបានសម្លាប់។ តែពុំមានការយោង សូម្បីតែមួយទៅលើសាច់រឿងនេះបង្ហាញនៅកន្លែងណាមួយក្នុងសំណុំរឿង ទោះជាក្នុងទម្រង់ណានោះ។ សហព្រះរាជអាជ្ញាខកខានមិនបានបង្ហាញសាកសពជនរងគ្រោះម្នាក់ឡើយ។ សំ សិទ្ធី ឬ សហព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណី មិនអាចចង្អុលឈ្មោះរងគ្រោះម្នាក់ ក្នុងចំណោមជនរងគ្រោះតាមសន្មតជាច្រើននាក់ ក្រៅពីតែពីការអះអាងរបស់ សំ សិទ្ធី ថាឪពុក-ម្តាយរបស់គាត់ក្នុងចំណោមជនរងគ្រោះដែរ។ តែនេះជាភស្តុតាងតែមួយគាំទ្រការសម្លាប់រង្គាលតាមការសន្មតនៅព្រៃរូងខ្លា ដែលជាចំណុចលេចធ្លោបំផុតនៅក្នុងសំណុំរឿង[19]។ ពុំមាន practitioner ដែលស្មោះត្រង់ និងមានបទពិសោធន៏ នឹងខកខានទទួលស្គាល់ការចន្លោះប្រហោងជាក់លាក់នៅក្នុងភស្តុតាង ថាជាការដាក់កម្រិតយ៉ាងច្រើនលើលទ្ធភាពរបស់សហព្រះរាជអាជ្ញាក្នុងការរកភស្តុតាងគាំទ្រដល់ករណីរបស់ខ្លួន។

៦. ក្នុងអំឡុងពេលនៃការជំនុំជម្រះក្រុមមេធាវីការពារក្តីបង្ហាញក្តីបារម្ភថា បទដ្ឋានធម្មតាដែលអនុវត្តចំពោះការវាយតម្លៃភស្តុតាងនៅតុលាការនេះ ហាក់ដូចជារអិលពីកណ្តាប់ដៃរបស់យើងខ្ញុំ។ ក្រុមមេធាវីការពារក្តីលើកអំណះអំណាងដូចខាងក្រោម:

---

[18] សូមមើល F17/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង០០២/០១ នៅកថាខណ្ឌ ៥១ (ដោយទទួលស្គាល់សារសំខាន់នៃលំនាំភស្តុតាងតាមការសន្មតនេះចំពោះការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងគោលនយោបាយកំណត់មុខសញ្ញាសហឧក្រិដ្ឋកម្ម។

[19] មកដល់ពេលនេះគោលនយោបាយកំណត់មុខសញ្ញាទាហាន និង មន្ត្រីសាធារណខ្មែរ សម្រាប់ការសម្លាប់នៅក្រោយការរំដោះ។

ជាមេធាវីការពារក្ដី យើងខ្ញុំមានការថប់បារម្ភណ៍តែមួយគត់អំពីភស្ដុតាងដែលត្រូវបានបង្ហាញអំពីគោលនយោបាយតាមការសន្មត់ក្នុងការសម្លាប់ទាហាន និងមន្ដ្រី លន់ ណុល។ នេះមិនមែនដោយសារថាភស្ដុតាងខ្លាំងទេ តែភស្ដុតាងខ្សោយខ្លាំងណាស់ វាខ្សោយពេកដែលយើងខ្ញុំបានផ្សំនៅក្នុងបន្ទប់សវនាការនេះទៅហើយ។ ដោយប្រើវោហារភាសាអង់គ្លេស យើងខ្ញុំភ័យខ្លាចថាព្រះរាជអាជ្ញាកំពុង "ផ្លាស់ប្ដូរវិធាន (moving goalpost)"។ និយាយម្យ៉ាងទៀតពួកគេកំពង់ផ្លាស់ប្ដូរបទដ្ឋាន ដែលប្រភេទនៃការចោទប្រកាន់ទាំងនេះ ត្រូវបានវិនិច្ឆ័យតាមធម្មតា[20]។

៧. ការផ្លាស់ប្ដូរវិធាន(moving goalpost) កាន់តែជាក់ស្ដែងច្រើនជាងនៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាដែលពួកគេអះអាងថា នៅក្នុង"ករណីបែបនេះ" ការស្វែងរកសាកសពជនរងគ្រោះ និងការថ្លឹងថ្លែងភស្ដុតាងបញ្ជាក់ មិនមែនជា "ទម្លាប់អនុវត្តធម្មតាទេ"[21]។ ការក្លែងបន្លំជាក់ស្ដែងនៃការអះអាងនេះ កើតចេញពីសេចក្ដីសន្និដ្ឋានរបស់ពួកគេផ្ទាល់ដែលជម្រុញឲ្យអង្គជំនុំជម្រះនេះ កត់សំគាល់សក្ខីកម្មនៅតុលាការ ICTY ដែលពួកគេអះអាងថា អាចប្រដូចគ្នាបានទៅនឹងសក្ខីកម្មរបស់ សំ សិទ្ធី។ តែបើពិនិត្យសារឡើងវិញឲ្យបានដិតដល់យុត្តិសាស្ត្រដែលពួកគេបានពឹងផ្អែក (សូមមើលខាងលើ) គ្រាន់តែបង្ហាញពីការប្រយ័ត្នប្រយែងជាមួយនឹងការប្រព្រឹត្តមកលើភស្ដុតាងនេះ និងភស្ដុតាងបញ្ជាក់ដ៏ច្រើនដើម្បីគាំទ្រវាប៉ុណ្ណោះ។ នេះប្រហែលមកពីភាពអសមត្ថភាពបំផុតរបស់សហព្រះរាជអាជ្ញា ដើម្បីយល់សារសំខាន់ដ៏ធំធេងរបស់សំណើនេះ ហើយទីបំផុតបញ្ហានានានៅក្នុងបណ្ដឹងសាទុក្ខ។ គ្មានមន្ទិលសង្ស័យទេ តែងតែមានការខ្វះខាតចំពោះសាក្សីមិនធម្មតាដែលបានផ្ដល់សក្ខីកម្មនៅក្នុងការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌនៅកម្រិតអន្តរជាតិ ឬកម្រិតជាតិ។ បញ្ហាមិននៅត្រង់ថា តើសាក្សីបាន និយាយអ្វីនោះទេ តែវានៅត្រង់ថា តើភស្ដុតាងត្រូវប្រព្រឹត្តដោយរបៀបណាទៅវិញទេ។

៨. ដូចដែលសហព្រះរាជអាជ្ញាបានកត់សម្គាល់ សាក្សី "Q" ដែលបានផ្ដល់សក្ខីកម្មនៅក្នុងករណី *Krstić* ដែលរួចផុតពីការសម្លាប់រង្គាលនៅ"កន្លែងឃុំឃាំងសាលា Pilica"[22]។ នៅក្នុងសាល

---

[20] T. 08 ០៨ កក្កដា ឆ្នាំ ២០១៣ (ប្រតិចារិកនៅក្នុងសំណុំរឿង០០២/០១ **E1/219.1**), នៅទំព័រ៤៦, lns. 20 – ទំព័រ 47, lns. 3

[21] **F28/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញានៅកថាខណ្ឌ៣៥។

[22] **F28/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញានៅជើងទំព័រទី៦៥។ ។

ក្រុម *Krstić* កន្លែងឃុំឃាំងសាលា Pilica គឺជាទីតាំងឧក្រិដ្ឋកម្មទីប្រាំពីរដែលត្រូវបានចាត់ទុកថា ជាផ្នែកនៃការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងលើតួនាទីរបស់អង្គភាព Drina Corps នៅក្នុងការសម្លាប់បុរសម៉ូស្លីមប៊ូស្នៀមកពីទីក្រុង Srebenica។ ការវាយតម្លៃរបស់អង្គជំនុំជម្រះនៃទីតាំងឧក្រិដ្ឋកម្មនីមួយៗទាំងប្រាំមួយ រួមទាំងការវិភាគលំអិតសក្ខីកម្មរបស់សាក្សីផ្ទាល់ភ្នែក ដែលផ្តល់សក្ខីកម្មដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ និងការវិភាគបែបកោសលវិច្ច័យផ្អែកលើការគាស់សាកសពពីរណ្តៅរួម។ អង្គជំនុំជម្រះវិភាគការទទួលខុសត្រូវផ្ទាល់ខ្លួនៗរបស់អង្គភាព Drina Corps សម្រាប់ការសម្លាប់នីមួយៗ ដោយធ្វើការសន្និដ្ឋានជាច្រើនដងថា ការទទួលខុសត្រូវមិនអាចឲ្យលើសពីវិមតិសង្ស័យលើមូលដ្ឋាននៃភស្តុតាងឡើយ[23]។ នៅពេលអង្គជំនុំជម្រះនៅក្នុងករណី *Krstić* យោងការវិភាគរបស់ខ្លួននៃកន្លែងឃុំឃាំងសាលា Pilica ជាដំបូងអង្គជំនុំជម្រះពឹងផ្អែកលើសក្ខីកម្មរបស់សាក្សី Drazen Erdemović ទាហានដែល "បានចូលរួមនៅក្នុងការសម្លាប់" ដែលបានសារភាពពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបានពិពណ៌នាពីតួនាទីរបស់គាត់នៅក្នុងការសម្លាប់នោះ[24]។ នៅក្រោយការពិពណ៌នាសក្ខីកម្មរបស់ Erdemović សាក្សី Q និង សាក្សីទីពីរដែលរួចផុតពីការសម្លាប់ដែរ អង្គជំនុំជម្រះនៅក្នុងករណី *Krstić* រកឃើញថា "សក្ខីកម្មរបស់អ្នករួចផុតពីការសម្លាប់មានការគាំទ្រផ្សេងទៀតនៅក្នុងកំណត់ត្រាជំនុំជម្រះ"។ "ការគាំទ្រផ្សេងទៀត" រួមបញ្ចូលទាំងក្នុងបញ្ហាផ្សេងទៀត រូបថតពីអាកាសដែលបង្ហាញសាកសពដ៏ច្រើន ការធ្វើកោសលវិច័យលើសាកសពបង្ហាញថា "បុព្វហេតុនៃការស្លាប់អាចត្រូវបានកំណត់ថា ជាការបាញ់ដោយគ្រាប់កាំភ្លើង"។ សាកសព៨៣ត្រូវគេចងផ្តោបគ្នា ហើយសាកសពពីរត្រូវគេរុំភ្នែក ហើយ "នៅក្នុងរណ្តៅមួយនេះអត្តសញ្ញាណកម្មមានភាពវិជ្ជមាន [...] សម្រាប់មនុស្ស១៣នាក់ដែលបាត់ខ្លួននៅក្រោយការកាន់កាប់ទីក្រុង Srebenica។ ពួកគេទាំងអស់គឺជាបុរសម៉ូស្លីមប៊ូស្នៀ"[25]។ ខណៈដែលភស្តុតាងដែលពិចារណា ដោយអង្គជំនុំជម្រះនៅក្នុងករណី

---

[23] សូមមើលឧទាហរណ៍រដ្ឋអជ្ញា តទល *Krstić,* Case No. IT-98-33-T សាលក្រមថ្ងៃទី0២ ខែសីហា ឆ្នាំ២00១ ("សាលក្រមនៅក្នុងសំណុំរឿង *Krstić* ) នៅកថាខណ្ឌ២00, ២0៤។

[24] សាលក្រមនៅក្នុងសំណុំរឿង *Krstić* នៅកថាខណ្ឌ២៣៤។

[25] សាលក្រមនៅក្នុងសំណុំរឿង *Krstić* នៅកថាខណ្ឌ២៣៤៧។

*Krstić* ទាក់ទងនឹងកន្លែងឃុំឃាំងសាលា Pilica មានភាពទូលំទូលាយពេក ដែលការរៀបរាប់ពេញលេញនឹងតម្រូវចម្លើយតបនេះទាំងស្រុង តែការវិភាគរបស់អង្គជំនុំជម្រះបន្តប្រាំមួយកថាខណ្ឌទៀត។ អង្គជំនុំជម្រះនៅក្នុងករណី *Krstić* បានវិភាគទីតាំងឧក្រិដ្ឋកម្មច្រើនជាងដប់។ នៅក្នុងករណីនេះអង្គជំនុំជម្រះសាលាដំបូងរកឃើញ នួន ជា ទទួលខុសត្រូវចំពោះការសម្លាប់តាមការសន្មតនៅព្រៃរូងខ្លា ដោយផ្អែកលើកំណត់ហេតុស្តាប់ចម្លើយសាក្សីម្នាក់នៅក្រៅតុលាការ និងគ្មានភស្តុតាងបញ្ជាក់ ដែលឈ្មោះរបស់គាត់មិនបង្ហាញនៅក្នុងសាលក្រមទៀតផង។ *ឈ្មោះទីតាំងឧក្រិដ្ឋកម្ម* មិនមានទីកន្លែងណាមួយនៅក្នុងសាលក្រមដែរ។

៩. ការវិភាគនេះ គឺស្រដៀងនៅក្នុងករណី *Krajišnik* ឧទាហរណ៍ទីពីរដែលផ្តល់ដោយសហព្រះរាជអាជ្ញា[26]។ នៅក្នុងករណី *Krajišnik* អង្គជំនុំជម្រះសាលាដំបូង ICTY វិភាគភស្តុតាងនីមួយៗនៃបទចោទប្រកាន់នានានៅក្រុងនីមួយៗទាំង៣៣នៅទូទាំង Bosnia-Herzegovina[27] ដូចនៅក្នុងរឿងក្តី *Krstić* ដែរអង្គជំនុំជម្រះនៅក្នុងករណី *Krajišnik* ពឹងផ្អែកយ៉ាងច្រើនលើសក្ខីកម្មរបស់សាក្សីផ្ទាល់ភ្នែក[28] ដោយបានបញ្ចូលការរកឃើញពីចំនួន និងអត្តសញ្ញាណរបស់អ្នកដែលត្រូវគេសម្លាប់ ឬអ្នកដែលត្រូវគេធ្វើទុក្ខបុកម្នេញនៅទីតាំងច្បាស់លាស់នានានៅទីក្រុងនីមួយៗ[29]។ សក្ខីកម្មរបស់អ្នកនៅរស់ជាក់លាក់ដែលត្រូវបានកំណត់អត្តសញ្ញាណដោយព្រះរាជអាជ្ញា ទាក់ទងនឹងព្រឹត្តិការណ៍នានានៅទីក្រុង Kalinovik ជាទីតាំងទី២៩នៅក្រោមការពិចារណានៅក្នុងសាលក្រម[30]។ ឧប្បត្តិហេតុដោយឡែកដែលពិពណ៌នាដោយសាក្សីម្នាក់

---

[26] ដូចដែលបណ្តឹងសាទុក្ខបង្ហាញ: សាលក្រមនៅក្នុងករណី *Krajišnik* បង្ហាញយុត្តិសាស្ត្ររបស់ខ្លួនយ៉ាងច្បាស់ ដោយលើកឡើងថា "ជាទូទៅអង្គជំនុំជម្រះមិនពឹងផ្អែកលើភស្តុតាងដែលជាពាក្យចាមអារាមអនាមិកនោះទេ។ ចំណុចនេះមិនដូចអង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណី០០២/០១ ដែលបានលើកមកសំអាងពាក្យចាមអារាមអនាមិក ភស្តុតាងក្រៅតុលាការ ព្រមទាំងគ្មានការពន្យល់ ការវិភាគ និងការពិភាក្សានោះទេ។ សូមមើលបណ្តឹងសារទុក្ខនៅកថាខណ្ឌ១៦៤, ១៧០។

[27] រឿងក្តីរវាងរដ្ឋអាជ្ញា តទល់ *Krajišnik*, សំណុំរឿងលេខ Case No. IT-00-39-T សាលក្រមចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០០៦, ("សាលក្រមនៅក្នុងករណី *Krajišnik* នៅកថាខណ្ឌ១១៣-៧០១។

[28] សូមមើលឧទាហរណ៍សាលក្រម *Krajišnik* ជើងទំព័រលេខ 686-695, 711-719, 739-745

[29] សូមមើលឧទាហរណ៍សាលក្រម *Krajišnik* នៅកថាខណ្ឌ 309, 320, 337

[30] សាលក្រម *Krajišnik* ជើងទំព័រលេខ 660-667

ត្រូវបានបញ្ជាក់ដោយកំណត់ហេតុស្តាប់ចម្លើយសាក្សីផ្សេងនៅក្រៅតុលាការ[31] ត្រូវបានបំពេញបន្ថែមដោយអង្គហេតុដែលត្រូវបានវិនិច្ឆ័យរួចមកហើយ និងត្រូវបានបង្ហាញឲ្យហួសពីវិមតិសង្ស័យទាក់ទងនឹងឧប្បត្តិហេតុស្រដៀងគ្នានៅក្នុងទីក្រុងតែមួយ[32]។

១០. ខណៈភាពខុសគ្នាជាក់ស្តែងរវាងសាលក្រមនៅក្នុងករណីនេះ និងសាលក្រមដែលពឹងផ្អែកដោយសហព្រះរាជអាជ្ញាមានច្រើនសន្ធឹក ការលើកសរសើរពេញលេញចំពោះការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងមិនបានវាយតម្លៃធ្ងន់ៗនៃភស្តុតាង គឺត្រូវតែលើកសរសើរតាមរយៈការពិនិត្យមើលយ៉ាងហ្មត់ចត់នៃភស្តុតាងពាក់ព័ន្ធ។ អ្នកអានបើទោះបីជាថ្មីកនឹងសាលក្រមនៅក្នុងករណីនេះ ក៏មិនអាចជួយបានដែរ តែនឹងចាប់អារម្មណ៍ដោយគុណភាពរបស់ភស្តុតាង និងភាពជាក់លាក់នៃការវិភាគនៅក្នុងករណី *Krstić* និង *Krajišnik* ករណីយុត្តិសាស្ត្រដែលសហព្រះរាជអាជ្ញាបានលើកជាអំណះអំណាង ប្រសិនបើសម្រាលអង្គជំនុំជម្រះនេះអំពីសក្ខីកម្មរបស់ សំ សិទ្ធី។ អង្គហេតុដែលថាសាក្សី Q បានផ្តល់សក្ខីកម្មនៅក្នុងការជំនុំជម្រះមួយ ហើយ សំ សិទ្ធី បានផ្តល់សក្ខីកម្មនៅការជំនុំជម្រះផ្សេង-ដូចអង្គហេតុដែលថាកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី សំ សិទ្ធី ហាក់ដូចជាមិនបានកើតឡើងពីការបោកបញ្ឆោតដោយចេតនា- ក៏មិនបានដោះស្រាយកាតព្វកិច្ចនៅពេលនេះនៅចំពោះមុខអង្គជំនុំជម្រះនេះដែរ។

១១. ការបិទបាំងនៅក្នុងស្រមោលនៃចម្លើយតបរបស់សហព្រះរាជអាជ្ញា គឺជាការសន្មតដែលមិនប្រកាសមួយគូថា គ្មានមេធាវីរូបណាក្លាហានធ្វើការប្រកាសថា បទពិសោធន៍ដែលពិពណ៌នានៅក្នុងសក្ខីកម្មរបស់ សំ សិទ្ធី គឺអាក្រក់ក្រៃលែង ដែលគាត់មិនអាចប្រឌិតបានឡើយ ហើយថា នួន ជា គឺមានពិរុទ្ធភាពយ៉ាងជាក់ស្តែង ដែលគាត់ត្រូវតែបានតាំងចិត្ត។ ពុំមានការពន្យល់ផ្សេងទៀតទេចំពោះការអះអាងឥតអៀនខ្មាស់របស់សហព្រះរាជអាជ្ញាថា សក្ខីកម្មគ្មានការបញ្ជាក់របស់សាក្សីផ្ទាល់ភ្នែកតែម្នាក់ចំពោះលំនាំនៃការប្រព្រឹត្តនៅទូទាំងប្រទេសតាមការសន្មត់ "គឺជឿទុកចិត្តបានជាទីបំផុត" ដែលការបញ្ជាក់នៃភស្តុតាងរបស់គាត់ គឺមិនចាំបាច់

[31] សាលក្រម *Krajišnik* ជើងទំព័រលេខ 1519-1523

[32] សាលក្រម *Krajišnik* ជើងទំព័រលេខ 1526-1528

ឡើយ។ សហព្រះរាជអាជ្ញា ជម្រុញស្វាត់ៗឲ្យអង្គជំនុំជម្រះនេះសន្និដ្ឋានថា សំ សិទ្ធី បានប្រាប់រឿងអាក្រក់មួយ អំពីបុរសអាក្រក់ម្នាក់ ហើយដូច្នេះគាត់កំពុងនិយាយការពិត។

១២. តថភាពនៅក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌអន្តរជាតិ គឺខុសគ្នា។ ពីព្រោះកម្លាំងជម្រុញរបស់ចម្លើយតបរបស់សហព្រះរាជអាជ្ញា គឺអាចមើលឃើញនៅក្នុងសាលក្រមថា បណ្តឹងសាទុក្ខរបស់យើងខ្ញុំ ប្រុងប្រយ័ត្នយ៉ាងខ្ពស់ចំពោះភាពគ្រោះថ្នាក់នៃការពឹងផ្អែកសក្ខីកម្មដែលគ្មានការបញ្ជាក់។ Nancy Combs បង្ហាញថា ភាពមិនស៊ីសង្វាក់គ្នានៅក្នុងសក្ខីកម្ម គឺជាប្រព័ន្ធនៅក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌអន្តរជាតិ ហើយប៉ះពាល់ "សាក្សីច្រើនចំនួនធំ"[33]។ Roel Burgler និង Michael Vickery បង្ហាញថា ជនភៀសខ្លួននៅព្រំដែនថៃ ត្រូវបានដាក់សំពាធឲ្យនិយាយបំផ្លើសពីរឿងរ៉ាវរបស់ពួកគេ ហើយថាជារឿយៗពួកគេនិយាយរឿងរ៉ាវនានាដែលបានផ្សព្វផ្សាយនៅក្នុងទីសាធារណៈ ហើយថាគេក៏បានប្រឌិតរឿងរ៉ាវអំពីប្រល័យពូជសាសន៍ ដែលជាការភូតកុហកទាំងស្រុង[34]។ សក្ខីកម្មរបស់ សំ សិទ្ធី គឺមិនជឿជាក់បំផុតនោះទេ ពិព្រោះគាត់ប្រាប់រឿងរ៉ាវអាក្រក់។

១៣. មិនដូចសហព្រះរាជអាជ្ញាទេ ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងហោចណាស់ស្វែងរកការចូលរួមលើកអំណះអំណាងនៅក្នុងសំណើ ទាក់ទងនឹងសារសំខាន់នៃសក្ខីកម្មរបស់ សំ សិទ្ធី ដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីលើកអំណះអំណាងថា អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែពិពណ៌នាកំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី ប៉ុន្តែមិនបានសម្រេចឲ្យហួសពីវិមតិសង្ស័យថា ការសម្លាប់ដែលគាត់ពិពណ៌នា បានកើតឡើងនោះទេ[35]។ តែដើមបណ្តឹងរដ្ឋប្បវេណីយល់ខុសពីវចនាសម្ព័ន្ធ និងការរកឃើញនៅក្នុងសាលក្រម។ ផ្ទុយពីការវិភាគរបស់ពួកគេអង្គជំនុំជម្រះ

---

[33] **F16**, បណ្តឹងសាទុក្ខ នៅកថាខណ្ឌ១១៨។

[34] **F16**, បណ្តឹងសាទុក្ខ នៅកថាខណ្ឌ១២០-១២២។

[35] **F28/1** ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅកថាខណ្ឌ ២៨-២៩។ អំណះអំណាងនេះទាក់ទងជាពិសេសនឹងការអះអាងរបស់ សំ សិទ្ធី ថាទាហានត្រូវបានសម្លាប់ បន្ទាប់ពីគេត្រូវបានប្រមូលផ្តុំ នេះគឺជាការដាក់ឲ្យចំកន្លែងតែមួយគត់ដែលពាក់ព័ន្ធនៅក្នុងសក្ខីកម្មរបស់គាត់។

សាលាដំបូងយល់ឃើញថា នួន ជា ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការសម្លាប់ជាក់លាក់ដែលពិពណ៌នានៅក្នុងសក្ខីកម្មរបស់ សំ សិទ្ធី[36]។

១៤. ពាក់កណ្តាលដំបូងនៃការវិភាគរបស់ដើមបណ្តឹងរដ្ឋប្បវេណីថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានវិភាគកំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី ហើយគ្រាន់តែអះអាងថា សាក្សីមួយចំនួនបានពិពណ៌នាការសម្លាប់-គឺពិតជាត្រឹមត្រូវ។ តាមពិតការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គហេតុនានាទាក់ទងនឹងការប្រព្រឹត្តមកលើទាហាន និងមន្ត្រីសាធារណខ្មែរក្នុងអំឡុងការជម្លៀសទីក្រុងភ្នំពេញ-នៅកថាខណ្ឌ៥០១ដល់៥១៥ នៃសាលក្រម-បញ្ជៀសយ៉ាងប្រយ័ត្នប្រយែងពីការរកឃើញណាមួយឲ្យហួសពីវិមតិសង្ស័យដែលថា ទាហានត្រូវបានសម្លាប់។ ជាមួយការលើកលែងប្រយោគតែមួយនៅក្នុងកថាខណ្ឌ៥០៧ រាល់ការយោងចំពោះការសម្លាប់ គឺត្រូវបានបង្កើតឡើងជាការពិពណ៌នាពីភស្តុតាង ជំនួសឲ្យការរកឃើញឲ្យហួសពីវិមតិសង្ស័យ[37]។ កិច្ចដំណើរការនីតិវិធីរបៀបនេះអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងពិពណ៌នាភស្តុតាងក្នុងន័យមិនច្បាស់លាស់ ដោយបង្កើតការសំអាងភស្តុតាងនៅជើងទំព័រអក្សរ ដោយគ្មានការវាយតម្លៃពិតប្រាកដលើខ្លឹមសារ ភាពជឿជាក់ ឬភាពអាចទុកចិត្តបាន។ វាអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូង បញ្ជៀសការវិភាគម៉ឺងម៉ាត់ ដែលនឹងតម្រូវការរកឃើញឲ្យហួសពីវិមតិសង្ស័យ។

១៥. តែដើមបណ្តឹងរដ្ឋប្បវេណីយល់ច្រឡំថា អង្គជំនុំជម្រះសាលាដំបូងមិនបានប្រើការសង្ខេបនៃភស្តុតាងនៅក្នុងការផ្តន្ទាទោសចំពោះការសម្លាប់ និងការរកឃើញការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការធ្វើមនុស្សឃាតឡើយ។ អំណះអំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហាក់ដូចជាសន្មតថា រាល់ការរកឃើញនៅក្នុងសាលក្រមដែលរំលេចនៅក្រោមចំណងជើង "ការរក

---

[36] **F28/1**ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅកថាខណ្ឌ ២៨-២៩។

[37] សូមមើលឧទាហរណ៍ **E313**, សាលក្រមនៅកថាខណ្ឌ៥០៨ ("សក្ខីកម្មមួយចំនួនលើកឡើងថា ទាហានត្រូវបានយកទៅសម្លាប់នៅគ្រប់ទីកន្លែងផ្សេង"), ៥១១ ("បើតាម ស៊ុំ ជា អតីតមេបញ្ជាការកងវរសេនាធំ គួន ប្រាប់កងពលរបស់ ស៊ុំ ជា ឲ្យធ្វើការប្រកាសបែបនេះ ដើម្បីទាក់ទាញអតីតទាហាន លន់ ណុល ដែលក្រោយមកពួកគេ ត្រូវបានសម្លាប់"), ៥១៣ ("សក្ខីកម្មមួយពិពណ៌នារបៀបនៃការកំណត់អត្តសញ្ញាណអ្នកដែលជាទាហាន លន់ ណុល ត្រូវសម្លាប់នៅនឹងកន្លែងដោយទាហានខ្មែរក្រហម។

ឃើញផ្នែកច្បាប់" ពាក់ព័ន្ធតែចេតនាប្រព្រឹត្តរបស់ជនល្មើស[38]។ ពុំមានអ្វីនៅក្នុងអត្ថន័យនៃពាក្យ "ការរកឃើញផ្នែកច្បាប់" ឬនៅក្នុងភាសាដែលប្រើនៅក្នុងសាលក្រម គាំទ្រការបកស្រាយនេះទេ។ វាច្បាស់ណាស់ថា "ការរកឃើញផ្នែកច្បាប់" ពាក់ព័ន្ធឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ទាក់ទងនឹងការជន្លៀសទីក្រុងភ្នំពេញ- មានចែងនៅក្នុងកថាខណ្ឌ៥៤៦ ដល់កថាខណ្ឌ៥៧៤ នៃសាលក្រម-រួមបញ្ចូលទាំងការរកឃើញទាំងអំពើពិរុទ្ធ និងចេតនាប្រព្រឹត្តនៃបទឧក្រិដ្ឋនីមួយៗដែលត្រូវបានចោទប្រកាន់ ត្រូវបានបំពេញ។ ការរកឃើញផ្នែកច្បាប់ទាំងនេះរួមបញ្ចូលការសន្និដ្ឋាននៅក្នុងកថាខណ្ឌ៥៥៣ ថាអំពើពិរុទ្ធសម្រាប់ការធ្វើមនុស្សឃាត ត្រូវបានបំពេញ ពិព្រោះ "ជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណថាជាទាហាន ឬមន្ត្រីសាធារណរដ្ឋខ្មែរក្នុងអំឡុងពេលការជន្លៀស ត្រូវបានយកទៅសម្លាប់នៅកន្លែងផ្សេង"។ ការរកឃើញនេះផ្អែកលើការវិភាគនៅក្នុងកថាខណ្ឌ៥១១ ដែលរួមបញ្ចូលទាំងការសំអាងលើកំណត់ហេតុស្តាប់ចម្លើយរបស់ សំ សិទ្ធី។ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីយល់ច្រឡំថា អង្គជំនុំជម្រះសាលាដំបូង មិនបានដាក់ឲ្យ នួន ជា ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការសម្លាប់ តាមការសន្មតដែលពិពណ៌នានៅក្នុងសក្ខីកម្មរបស់ សំ សិទ្ធី[39]។

១៦. ដូច្នេះសារសំខាន់នៃអំណះអំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺថាវាគួរលំលេចពីការវិភាគភស្តុតាងមិនបានគ្រប់គ្រាន់ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសាលក្រម។ អង្គជំនុំជម្រះសាលាដំបូងនិយាយតិចតួចអំពីការសម្លាប់នៅព្រៃវែងខ្លា ហើយភាគីដែលស្វែងរកការផ្តន្ទាទោសចំពោះការសម្លាប់នៅព្រៃវែងខ្លា ជ្រើសរើសលើកអំណះអំណាងដែលលំអិត និងមិនសមហេតុ

[38] **F28/1** សារណាឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅកថាខណ្ឌ២៨។

[39] ក្រុមមេធាវីការពារក្តីកត់សម្គាល់បន្ថែមទៀតថា សហព្រះរាជអាជ្ញាលើកអំណះអំណាងស្រដៀងនៅក្នុងសារណាឆ្លើយតបរបស់ពួកគេទៅនឹងបណ្តឹងសារទុក្ខ ដោយចោទប្រកាន់ថាសាលក្រមបានបញ្ចូលការវិនិច្ឆ័យទោសសម្រាប់ការធ្វើមនុស្សឃាត សម្រាប់ការសម្លាប់មនុស្សនីមួយៗ តែជាជាងការផ្តន្ទាទោសតែមួយសម្រាប់ការសម្លាប់រង្គាលដោយផ្អែកលើភស្តុតាងទាំងមូល។ សូមមើល F17/1 នៅកថាខណ្ឌ១៤៥។ សម្រាប់មូលហេតុដែលត្រូវពិភាក្សាលំអិតនៅក្នុងចម្លើយតបនេះទៅនឹងសារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញា អំណះអំណាងនេះគឺជាការយល់ខុសសាលក្រម ដែលរកឃើញយ៉ាងច្បាស់ថា នួន ជា ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការធ្វើមនុស្សឃាត ជាប់ពាក់ព័ន្ធជាមួយការសម្លាប់នីមួយៗ ដែលបានពិពណ៌នានៅក្នុងការរកឃើញផ្នែកអង្គហេតុរបស់សាលក្រម។

ផលថា អង្គជំនុំជម្រះសាលាដំបូងមិនបានរកឃើញថា ការសម្លាប់កើតឡើងទេ តែព្យាយាមបង្ហាញឲ្យឃើញថា វាជាការសមរម្យក្នុងការធ្វើបែបនេះ។ ការវិភាគភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង មានកម្រិត និងមិនធ្ងន់ធ្ងរថា ភាគីអាចអានសាលក្រម និងសន្និដ្ឋានក្នុងន័យសុច្ចរិតថា អង្គជំនុំជម្រះ *មិនពឹងផ្អែកវាទេ*។ ការផ្ទុយពីករណី *Krstić* និង *Krajišnik* គឺមិនធម្មតា។

១៧. ប្រសិនបើការបកស្រាយសាលក្រមរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រឹមត្រូវ នោះការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូងនៃការទទួលខុសត្រូវព្រហ្មទណ្ឌ កាន់តែមិនទាក់ទងគ្នាជាងអ្វីដែលក្រុមមេធាវីការពារក្តីធ្លាប់ជឿទៅទៀត។ ជាការពិតប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមិនរកឃើញឲ្យហួសពីវិមតិសង្ស័យដែលថា មានការសម្លាប់នៅព្រៃវែងខ្លាទេ អង្គជំនុំជម្រះសាលាដំបូង មិនអាចជឿការសម្លាប់ទាំងនេះបានទេ សម្រាប់គោលបំណងដាក់បញ្ចូលនៅក្នុងការផ្តន្ទាទោស- ប្រាកដណាស់មិនចាំបាច់បង្ហាញចេតនារបស់ជនដែលដូចដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើនៅក្នុងសាលក្រម (ចេតនាធ្វើអ្វី បើសិនជាគ្មាននរណាម្នាក់ត្រូវបានគេធ្វើមនុស្សឃាតផងនោះ?)។ ដូចដែលបានបង្ហាញនៅក្នុងកថាខណ្ឌ ១៤ ខាងលើ វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះកំណត់ហេតុស្តាប់ចម្លើយ សំ សិទ្ធី មិនមែនជាករណីលើកលែងទេ-អង្គជំនុំជម្រះមិនបានរកឃើញឲ្យច្បាស់ ឲ្យហួសពីវិមតិសង្ស័យទេនៅក្នុង "ការរកឃើញអង្គហេតុរបស់ខ្លួន" ទាក់ទងនឹងការប្រព្រឹត្តមកលើទាហាន និងមន្ត្រីរបស់សាធារណរដ្ឋក្នុងអំឡុងពេលជម្លៀសទីក្រុងភ្នំពេញ។ អំពីការវិភាគរបស់ដើមបណ្តឹងរដ្ឋប្បវេណីវិញ អង្គជំនុំជម្រះសាលាដំបូងបញ្ចូលក្នុងការផ្តន្ទាទោសចំពោះការសម្លាប់រង្គាល ហើយ នួន ជា ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការធ្វើមនុស្សឃាត ប៉ុន្តែរកឃើញស្ទើរតែគ្មានការធ្វើមនុស្សឃាតណាមួយផងនោះ។ ការពន្យល់សមហេតុផលតែមួយគត់ គឺថាបើអង្គជំនុំជម្រះសាលាដំបូង សម្រេចថាមានសក្ខីកម្មគ្រប់គ្រាន់នៅក្រៅតុលាការ មិនមានការបញ្ជាក់ និងជាពាក្យចាមអារាមពីការធ្វើមនុស្សឃាត ដែលយ៉ាងហោចណាស់សក្ខីកម្មមួយចំនួន គឺជាសក្ខីកម្មពិត។ ការវិភាគនេះជារំលោភធ្ងន់ធ្ងរ និងជាក់ស្តែងលើសច្ចធាករណ៍នៃការគ្មានទោស។

## ខ. សហព្រះរាជអាជ្ញាប្រើកលយុទ្ធបន្លាច ដើម្បីបញ្ចៀសការវាយតម្លៃម៉ឹងម៉ាត់ភស្តុតាង

១៨. សហព្រះរាជអាជ្ញាក្រើនរំលឹកពីដំណើរនៃការវន្ធត់ ដែលនឹងកើតឡើងបន្ទាប់ពីដំណោះស្រាយដែលបានស្នើឡើងនៅក្នុងសំណើនេះ និងអះអាងថាផលវិបាកទាំងនេះស៊ីសង្វាក់ជាមួយ "ការប៉ុនប៉ងរបស់ នួន ជា ដើម្បីពន្យារកិច្ចដំណើរការនីតិវិធី" និងធានាថាអង្គជំនុំជម្រះនេះនឹងមិនសម្រេចបាននូវសេចក្តីសម្រេចឡើយ[40]។ សហព្រះរាជអាជ្ញាក្រើនរំលឹកថា បើសិនអង្គជំនុំជម្រះនេះស្តាប់ចម្លើយសាក្សីបន្ថែម វានឹងនាំឲ្យមានសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀតទៅលើព្រឹត្តិការណ៍នានាតាមការសន្មត ដែលបានពិពណ៌នានៅក្នុងសក្ខីកម្មរបស់ សំ សិទ្ធី[41]។ ការបំផ្លើសរបស់ពួកគេទៅដល់ចំណុចខ្ពស់ដោយអះអាងថា "ការនិយាយស្មានៗពីវិធីសាស្ត្ររបស់ នួន ជា នៅទីនេះទៅកាន់សាក្សីដែលសក្ខីកម្ម ឬ កំណត់ហេតុស្តាប់ចម្លើយរបស់ពួកគេត្រូវបានសំអាងនៅក្នុងសាលក្រម នឹងតម្រូវឲ្យអង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធដំណើរការច្រំដែល និង មិនចេះចប់ច្រើនឆ្នាំទៀត"[42]។

១៩. ការក្រើនរំលឹកធ្ងន់ៗ និង ឥតស្រាកស្រាន្ត មិនមានមូលដ្ឋានអ្វីទាំងអស់ តែជាមនោគតិសកម្មរបស់សហព្រះរាជអាជ្ញាទៅវិញទេ។ អង្គហេតុសាមញ្ញគឺថា ក្រុមមេធាវីការពារក្តីបានស្វែងរកការស្តាប់សក្ខីកម្មនៅក្នុងបណ្តឹងសាទុក្ខ សាក្សីម្នាក់ដែលសក្ខីកម្មរបស់គាត់ត្រូវបានសំអាងនៅក្នុងសាលក្រម ហើយសាក្សីនេះគឺ សំ សិទ្ធី។ ដូចដែលបានបង្ហាញរួចហើយ សំអាងហេតុនៅក្នុងការគាំទ្រសំណើនេះ ត្រូវបានពិភាក្សាលំអិត និងពង្រីកឲ្យហួសពីចំណុចខ្វះខាតនៅក្នុងខ្សែអាត់ថតសំលេងនៃការស្តាប់ចម្លើយ សំ សិទ្ធី[43]។ សំណើផ្សេងទៀតសុំស្តាប់សក្ខីកម្មសាក្សីផ្សេងទៀតនៅចំពោះអង្គជំនុំជម្រះនេះ ទាំងនៅក្នុងសារណាបណ្តឹងសាទុក្ខ និងសំណើក្រោយៗ សុំទទួលយក និង ទទួលបានភស្តុតាង-ដែលសំណើនីមួយៗមានសំអាងហេតុស្មើគ្នា-មានភស្តុតាងដែលពាក់ព័ន្ធទាំងអស់ ដែលអង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណា

---

[40] **F28/2** សារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ ៣៣។

[41] **F28/2** សារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ ៣៤។

[42] **F28/2** សារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ ៣៤។

[43] សូមមើលកថាខណ្ឌ ៣ ខាងលើ។

នៅក្នុងសាលក្រម។ សំណើទាំងនេះមានមូលដ្ឋាននៅក្នុងសិទ្ធិរបស់ នួន ជា ដើម្បីបង្ហាញការ ការពារក្តី និង ការខកខានជាប្រព័ន្ធក្នុងការពិចារណាភស្តុតាងដោះបន្ទុកនៅក្នុងសាលក្រម ដែលជាសនិទានភាពខុសគ្នាទាំងស្រុងពីអំណះអំណាងនៅក្នុងសំណើនេះ។ ទោះជានៅក្នុង ករណីណាក៏ដោយ កិច្ចការពារសាមញ្ញប្រឆាំងនឹងវាយលុកដ៏ស្រួចស្រាវ ដែលបានព្យាករ ដោយសហព្រះរាជអាជ្ញា: ប្រសិនសំណើដែលពួកគេស្នើ សម្រេច ហើយអង្គជំនុំជម្រះនេះ រកឃើញ សំណើទាំងនេះមិនមានអង្គសេចក្តី នោះអង្គជំនុំជម្រះនេះអាចសម្រេចបដិសេធ។

២០. ការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងភាពស្មុគស្មាញក្នុងការស្វែងរកវត្ថុតាងគឺជា ការប្រើពាក្យសំដីមិនសមរម្យ[44]។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា "មានរណ្តៅសាកសព រាប់ពាន់រណ្តៅនៅកម្ពុជា សំណួរសួរថាហេតុអ្វីមិនមានសាកសពសូម្បីតែមួយ ត្រូវបានគាស់ ចេញពីរណ្តៅ ដើម្បីគាំទ្រដល់ការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ខណៈដែលប្រជា ជនជិត២លាននាក់ បានស្លាប់នៅរបបកម្ពុជាប្រជាធិបតេយ្យនោះ។ សំណើនេះមិនស្វែងរកឲ្យ កំណត់អត្តសញ្ញាណទីតាំងរណ្តៅរាប់ពាន់នោះទេ តែស្វែងរកឲ្យកំណត់អត្តសញ្ញាណទីតាំង រណ្តៅសាកសពមួយ ដែលអាចគាំទ្រដល់សក្ខីកម្មរបស់សាក្សីម្នាក់គត់ចំពោះលំនាំនៃការ ប្រព្រឹត្តតាមការសន្មតនៅទូទាំងប្រទេស។ បើសហចៅក្រមស៊ើបអង្កេតបានខ្នះខ្នែងពិនិត្យផ្នែក កោសលវិច្ច័យទាក់ទងនឹងផ្នែកតូចៗនៃបទឧក្រិដ្ឋដែលពួកគេចោទមកលើ នួន ជា សេចក្តី សន្និដ្ឋានរបស់យើងខ្ញុំនឹងធ្វើតាមប៉ារ៉ាម៉ែត្រ និងលទ្ធផលនៃការស៊ើបសួរជាសម្ភតិកម្ម។ សំណើ នេះអាចមិនស្វែងរកដំណោះស្រាយពិសេសនេះទេ។ ជាថ្មីម្តងទៀតសហព្រះរាជអាជ្ញាចូលរួម គំនិតអរូបីបែបវេីរវាយអំពីរណ្តៅសាកសព និងសាក្សី តែតាមការពិតនៅក្នុងភស្តុតាងពុំមាន *រណ្តៅសាកសព* និង *មានសាក្សីតែម្នាក់គត់*។ អង្គជំនុំជម្រះនៅក្នុងករណី *Krstić* និង *Krajišnik* មិនទទួលស្គាល់នៅក្នុងកំណត់ហេតុជំនុំជម្រះនៅក្នុងករណីនេះទេ។

២១. ខណៈដែលសហព្រះរាជអាជ្ញាអះអាងថា សក្ខីកម្មរបស់ សំ សិទ្ធី គឺ "ជឿទុកចិត្តបំផុត") តែ ទង្វើរបស់ពួកគេបង្ហាញផ្សេង។ ទង្វើរបស់សហព្រះរាជអាជ្ញាបង្ហាញថា ពួកគេចង់ពិភាក្សាឲ្យ បានតិចបំផុត តាមតែអាចធ្វើបាន អំពីសក្ខីកម្មរបស់ សំ សិទ្ធី។ បើទោះបីជាមានការប្រឆាំង

---

[44] **F28/2** សារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ៣៥។

ជំទាស់ដដែលៗពីក្រុមមេធាវីការពារក្តី ពួកគេសឹងតែមិនបានសួរសាក្សីអំពីការសម្លាប់រង្គាល ដែលបានចោទប្រកាន់ក្នុងអំឡុងពេលនៃការបង្ហាញខ្លួនរបស់សាក្សីនេះនៅចំពោះមុខអង្គជំនុំជម្រះនេះទេ។ នៅពេលសវនាការហៀបនឹងបញ្ចប់ មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះនេះ បង្គាប់ទៅសហព្រះរាជអាជ្ញា ឲ្យសួរដេញដោលសាក្សីនេះទាក់ទងនឹងគោលបំណងនៃការបង្ហាញខ្លួនរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះនេះ៖

> លោកប្រធាន សហព្រះរាជអាជ្ញាកំពុងធ្វើការចំអកមកលើអង្គជំនុំជម្រះនេះ។ វាធ្វើឲ្យអាប់កេរ្តិ៍ឈ្មោះនូវអ្វីដែលកំពុងកើតឡើង។ សូមមេត្តាអនុគ្រោះគមន៍[45]។

ម្តងទៀត៖

> យើងពិតជាមិនចាប់អារម្មណ៍នៅក្នុងឧប្បត្តិហេតុនេះទេ។ សូមមេត្តាប្រើប្រាស់នាទីចុងក្រោយរបស់លោកដាក់សំណួរទៅកាន់សាក្សីនេះអំពីការសម្លាប់រង្គាល លោកព្រះរាជអាជ្ញា[46]។

ចម្លើយតបរបស់សហព្រះរាជអាជ្ញា គឺជាការបន្តនៃកិច្ចប្រឹងប្រែងនេះ ដើម្បីបង្វែរការប្រុងស្មារតីឲ្យបានច្រើន តាមដែលអាចធ្វើបាន ពីខ្លឹមសារនៃសក្ខីកម្មរបស់ សំ សិទ្ធី។ ប្រសិនបើសហព្រះរាជអាជ្ញាជឿថា សក្ខីកម្មរបស់ សំ សិទ្ធី "ជឿជាក់ជាទីបំផុត" ពួកគេមិនគួរជំទាស់នឹងដំណោះស្រាយ ដែលបានស្នើឡើងនៅក្នុងសំណើនេះនៅក្នុងភារកិច្ចរបស់ពួកគេ ដើម្បីស្វែងរកការពិតទេ។ ស្លឹកល្វា (fig leaf) ដែលពួកគេប្រើដើម្បីលាក់បាំងកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីបញ្ចៀសការពិនិត្យសក្ខីកម្មរបស់ សំ សិទ្ធី ត្រូវបានបង្ហាញ តាមរយៈការបដិសេធរបស់ពួកគេមិនឆ្លើយតបទៅនឹងដំណោះស្រាយដែលបានស្នើឡើងនៅក្នុងសំណើនេះនោះគឺអង្គជំនុំជម្រះនេះអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តី នួន ជា អនុវត្តកិច្ចស៊ើបសួរដែលបានស្នើដោយខ្លួនឯង។

## គ. សហព្រះរាជអាជ្ញាធ្វើឲ្យអត់ថយខុសទៅលើភាពមិនស៊ីសង្វាក់គ្នានៅក្នុងសក្ខីកម្មរបស់ សំ សិទ្ធី

---

[45] T ៣កក្កដា ២០១៥ (ប្រតិចារិកនៃដំណើរការនីតិវិធីបណ្តឹងសារទុក្ខ), **F1/2.1**), p. 101, lns. 21-22

[46] T ៣កក្កដា ២០១៥ (ប្រតិចារិកនៃដំណើរការនីតិវិធីបណ្តឹងសារទុក្ខ), **F1/2.1**), p. 105, lns. 14-16

២២. ដូចដែលសំណើនេះបានបង្ហាញ សំ សុីទ្ធី និយាយច្រំដែលៗអស់៤០នាទីថា ប្រាំពីរគ្រួសារត្រូវបានគេបណ្តើរព្រមគ្នាពីវត្តច្រកស្តេច ទៅព្រៃរូងខ្លា ហើយឆ្លងស្ទឹងមួយ និងត្រូវគេសម្លាប់ទាំងអស់គ្នានៅពេលតែមួយ[47]។ សក្ខីកម្មនេះខុសគ្នាយ៉ាងជាក់ស្តែងពីសាច់រឿងដែល សំ សិទ្ធី បានផ្តល់ឱ្យសហចៅក្រមស៊ើបអង្កេត ដែលថាជាដំបូងបុរសពេញវ័យត្រូវបានបំបែកចេញពីក្រុម បន្ទាប់មកគាត់លួចដើរតាមឪពុករបស់គាត់ចូលក្នុងព្រៃ ហើយបានឃើញទាហានប្រដាប់ដោយកាំភ្លើងជាច្រើននាក់ ហើយបន្ទាប់មករត់ទៅប្រាប់ម្តាយរបស់គាត់ពីអ្វីដែលបានកើតឡើង ហើយក៏ត្រូវបានគេបណ្តើរត្រឡប់ក្រោយ ហើយឆ្លងស្ទឹងជាមួយតែស្រី និង កុមារៗ ហើយត្រូវគេបណ្តើរទៅទីតាំងសម្លាប់ និងបាញ់សម្លាប់នឹងកាំភ្លើង[48]។ ទើបតែនៅក្រោយ សំ សិទ្ធី ត្រូវបានរំលឹកព័ត៌មាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ទើបគាត់ប្តូរសាច់រឿងរបស់គាត់ ដើម្បីយកសក្ខីកម្មនេះនៅចំពោះមុខអង្គជំនុំជម្រះនេះ[49]។

២៣. ការឆ្លើយតប "សំខាន់បំផុត" របស់សហព្រះរាជអាជ្ញាចំពោះភាពផ្ទុយគ្នានៅក្នុងសក្ខីកម្មរបស់ សំ សិទ្ធី គឺថាសាក្សីនិយាយ "ច្រើន" ដងថាបានឆ្លងស្ទឹង ហើយឃើញទាហានប្រដាប់អាវុធនៅមុនពេលឆ្លើយយ៉ាងឆាប់រហ័សទៅកាន់មេធាវីការពារក្តីអំពីព័ត៌មាននេះ។ សេចក្តីសន្និដ្ឋានទាំងនេះ គឺគ្មានអ្វីខ្លីក្រៅពីការប្រឹងប្រែងដើម្បីធ្វើឱ្យភាន់ច្រឡំនូវកំណត់ហេតុ និងបំភ័ន្តអង្គជំនុំជម្រះនេះទេ។ សក្ខីកម្មដែលសហព្រះរាជអាជ្ញាពឹងផ្អែក គឺពាក់ព័ន្ធការឆ្លងស្ទឹងរបស់ សំ សិទ្ធី ជាមួយសមាជិកគ្រួសារទាំងអស់ទៅកាន់រណ្តៅបេ៥២ គឺទើបតែនៅមុនពេលត្រូវបានបាញ់-នៅក្នុងការរៀបរាប់របស់គាត់ក្រោយមកទៀត គឺនៅពេលគាត់ឆ្លងស្ទឹងលើកទីពីរ។ ដូច្នេះ សំ សិទ្ធី បាននិយាយថា "យើងឆ្លងស្ទឹង ឬអូរ ទៅទិសខាងត្បូង ហើយបន្ទាប់មកយើងឆ្លងអូរ ឬស្ទឹង <u>ទាហានមានអាវុធយកយើងទៅសម្លាប់</u>"[50]។ សំ សិទ្ធី បានផ្តល់សក្ខីកម្មថា "បន្ទាប់ពីយើងឆ្លងអូរ ឬស្ទឹង ទាហានមានអាវុធបណ្តើរយើងទៅរូងព្រៃរូងខ្លា <u>ហើយយើងត្រូវបានគេ</u>

---

[47] **F28** សំណើនៅកថាខណ្ឌ៩-១០។

[48] **F28** សំណើនៅកថាខណ្ឌ៤, ៩-១០។

[49] **F28** សំណើនៅកថាខណ្ឌ១១-១២។

[50] ប្រតិចារិកសវនាការ ថ្ងៃទី ៣ កក្កដា ឆ្នាំ២០១៥ (ប្រតិចារិកសវនការលើបណ្តឹងឧទ្ធរណ៍ **F1/2.1**) ទំព័រ២២ បន្ទាត់ ៨ ដល់១០។

សម្លាប់ទាំងអស់"[51]។ នៅក្នុងករណីនិមួយៗ សំ សិទ្ធី មិនបាននិយាយទៅដល់ការបំបែកចេញពីបុរសពេញវ័យនោះទេ នៅពេលឆ្លងស្ទឹង *ដើម្បីទៅតាមឪពុកគាត់* ពេលឃើញឪពុករបស់គាត់ត្រូវបានសម្លាប់ ពេលរត់ត្រឡប់មកម្តាយរបស់គាត់វិញ ឬក៏បានឃើញការសម្លាប់តែស្ត្រីនិងកុមារ។ នៅក្នុងករណីនិមួយៗ សំ សិទ្ធី បាននិយាយថា គ្រួសារ "ទាំងអស់" ទាំងប្រាំពីរគ្រួសារ ត្រូវបានសម្លាប់ទាំងអស់ក្នុងពេលតែមួយ[52]។ ការពិត សំ សិទ្ធី *ពិត* ជាបាននិយាយពីការឆ្លងស្ទឹង ប៉ុន្តែខកខានក្នុងការនិយាយថា គាត់បានឆ្លង*ពីរដង* គ្រាន់តែបង្ហាញពីភាពមិនស៊ីសង្វាក់គ្នា។ សក្ខីកម្ម "ដោយខ្លួនឯងនេះ" ដែលសហព្រះរាជអាជ្ញាអះអាងថា ស្តារឡើងវិញនូវសក្ខីកម្មរបស់ សំ សិទ្ធី គឺពិតជាបង្ហាញផ្ទុយពីនេះ។

២៨. សហព្រះរាជអាជ្ញាក៏អះអាងថា នៅក្នុងសក្ខីកម្មរបស់ សំ សិទ្ធិ ក្នុងរយៈពេល៤០នាទីមុនដំបូងគ្មានភាពផ្ទុយគ្នានឹង "សក្ខីកម្មលម្អិត" ក្រោយមកទៀតនោះទេ។ ការលើកឡើងបែបនេះ គឺមិនត្រឹមត្រូវនោះទេ។ សំ សិទ្ធី បាននិយាយបីដងថា សមាជិក"ទាំងអស់" ទាំង៧គ្រួសារ ត្រូវបានបាញ់សម្លាប់ទាំងអស់គ្នាក្នុងពេលដែលគាត់មានវត្តមាន។ អាស្រ័យហេតុនេះ គាត់ផ្តល់សក្ខីកម្មថា បន្ទាប់ពីឆ្លងអូរ ត្រូវបានបណ្តើរដោយទាហានមានអាវុធ "យើងទាំងអស់គ្នាត្រូវបានសម្លាប់"[53]។ គាត់និយាយថា "គេប្រាប់ឲ្យយើងទាំងអស់គ្នាអង្គុយជាក្រុម ទាំង៧គ្រួសារ"[54]។ គាត់បានផ្តល់សក្ខីកម្មថា បន្ទាប់មកដល់រណ្តៅបេ៥២ "យើងត្រូវបានបញ្ជាឲ្យអង្គុយជាក្រុម ហើយទាហានទាំងនោះបាញ់មកលើយើងទាំងអស់គ្នា"[55]។ ជាងនេះទៅទៀតនោះ នៅពេលសួរលម្អិតអំពីមានអ្វីបានកើតឡើងបន្ទាប់ពីដើរមកពីវត្តច្រកស្តេច សំ សិទ្ធី មានភាពមិនច្បាស់លាស់ដោយនិយាយថា "គ្មានអ្វីកើតឡើងទេព្រោះពួកគេទាំងអស់ហ្នឹងត្រូវបានសម្លាប់ហើយ"[56]

---

[51] ប្រតិចារិកសវនាការ ថ្ងៃទី ៣ កក្កដា ឆ្នាំ២០១៥ (ប្រតិចារិកសវនការលើបណ្តឹងឧទ្ធរណ៍ F1/2.1) ទំព័រ២៣ បន្ទាត់ ២២ ដល់២៣។

[52] ឯកសារ F28, សំណើ កថាខណ្ឌ ៩។

[53] ឯកសារ F28, សំណើ កថាខណ្ឌ ៩។

[54] ឯកសារ F28, សំណើ កថាខណ្ឌ ៩។

[55] ឯកសារ F28, សំណើ កថាខណ្ឌ ៩។

[56] ឯកសារ F28, សំណើ កថាខណ្ឌ ៩។

ពាក្យថា "គ្មានអ្វីកើតឡើង" ដែលបានកើតឡើងនេះ គឺនៅក្នុងការយល់ឃើញរបស់សហព្រះរាជអាជ្ញា គឺប្រហែលជាស៊ីសង្វាក់គ្នា នឹងលទ្ធផលដែលរន្ធត់ និងស្មុគស្មាញនៃព្រឹត្តិការណ៍ដែលគាត់ក្រោយមកបានអះអាងថា បានកើតឡើងយ៉ាងហោចណាស់ក៏ក្នុងរយៈពេលពីរម៉ោងនៅក្នុងព្រៃដែរ។ នៅពេលដែលត្រូវបានសួរដោយមេធាវីការពារក្តីអំពីថា តើមានការពិភាក្សាគ្នាដែរឬទេ រវាងឪពុករបស់គាត់ នឹង ទាហាន CPNLAF សំ សិទ្ធី បដិសេធក្នុងនិយាយថា ឪពុករបស់គាត់បានស្លាប់បាត់ទៅហើយ[57]។ ប្រសិនបើមានកំហុសដោយការលុប នេះគឺជាអ្វីដែលបាននិយាយ។

២៥. ការបំភ័ន្តបំផុតជាងនេះទៅទៀតនោះគឺ ការអះអាងរបស់សហព្រះរាជអាជ្ញាដែលថា សក្ខីកម្មរបស់ សំ សិទ្ធី ត្រូវបានរិតត្បិតតាមរយៈ "ការប៉ុនប៉ងច្រើនដងដោយមេធាវីការពារក្តីរបស់ នួន ជា នៅដំណាក់កាលស្តាប់សក្ខីកម្មរបស់ សំ សិទ្ធី ដើម្បីកំណត់វិសាលភាពនៃចម្លើយរបស់គាត់ និងបំបាក់ទឹកចិត្តក្នុងការពន្យល់"[58]។ ដូចកំណត់ហេតុបង្ហាញយ៉ាងច្បាស់ថា មេធាវីការពារក្តីបានជំរុញ សំ សិទ្ធី ជាដដែលៗឲ្យពន្យល់លម្អិតអំពីសក្ខីកម្មរបស់គាត់[59]។ មេធាវីការពារក្តីជួបមិនគ្រាន់តែការនៅស្ងៀមនោះទេ តែបានបញ្ជាក់ថា "គ្មានអ្វី" បានកើតឡើង[60]។

២៦. ចុងបញ្ចប់សហព្រះរាជអាជ្ញាព្យាយាមកាត់បន្ថយជា "អប្បបរិមា" នូវភាពមិនស៊ីសង្វាក់គ្នាជាច្រើននៅក្នុងសក្ខីកម្មរបស់ សំ សិទ្ធី ដែលលេចចេញពីកំណត់ហេតុដែលមិនអាចប្រកែកបាន[61] ភាពផ្ទុយគ្នានេះ គឺច្បាស់នៅក្នុងកំណត់ហេតុ ហើយមេធាវីការពារក្តី នឹងមិនឈប់ស្នើសុំនោះទេ។ ជាងនេះទៅទៀតនោះ គួរកត់សម្គាល់ថា សហព្រះរាជអាជ្ញា មិនមានយោងទៅសូម្បីតែ

---

[57] ឯកសារ **F28,** សំណើ កថាខណ្ឌ ១០។

[58] ឯកសារ **F28/2** , ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២០។

[59] ប្រតិចារិកសវនាការ ថ្ងៃទី ៣ កក្កដា ឆ្នាំ២០១៥ (ប្រតិចារិកសវនការលើបណ្តឹងឧទ្ធរណ៍, **F1/2.1** ) ទំព័រ១៨ បន្ទាត់ ២២ ទំព័រ ១៩ បន្ទាប់២ ទំព័រ ១១ បន្ទាត់ ២០ដល់២៣ ទំព័រ ២៣បន្ទាត់ ២៤ ទំព័រ២៤ បន្ទាត់ ៦ ដល់៨ ទំព័រ ២៧ បន្ទាត់ ១៦ ដល់២០។

[60] ឯកសារ **F28,** សំណើ កថាខណ្ឌ ៩។

[61] ឯកសារ **F28,** សំណើ កថាខណ្ឌ ១១ ដល់ ១៣ ។ ឯកសារ **F28/2** , ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១។

កំហុសមួយ អាស្រ័យហេតុនេះហើយខ្លួនមិនពេញចិត្តក្នុងការមិនពិភាក្សាសោះថា៖ សំ សិទ្ធី មិនអាចចាំឈ្មោះសូម្បីតែបងប្អូនរបស់គាត់ដែលត្រូវបានសម្លាប់[62]។

## ឃ. សហព្រះរាជអាជ្ញាបកស្រាយខុសលើបទដ្ឋានច្បាប់ជាធរមាន

២៧. សហព្រះរាជអាជ្ញា បានព្យាយាមប៉ុនប៉ងដោយបរាជ័យជាដដែលក្នុងការលួងលោមអង្គជំនុំជម្រះថា ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការទទួលយកភស្តុតាងថ្មីអំពីបណ្ដឹងសាទុក្ខគឺតម្រូវនៅក្នុងវិធាន ១០៨(៧)[63]។ ផ្ទុយពីអ្វីដែលលើកឡើងដោយសហព្រះរាជអាជ្ញាថា ការពិនិត្យរបស់អង្គជំនុំជម្រះនេះ អំពីប្រយោជន៍យុត្តិធម៌តាមវិធាន ១០៤(១) "ត្រូវតែចាំបាច់" រាប់បញ្ចូលទាក់ទងនឹងតេសនៅក្នុងវិធាន ១០៨(៧)[64] អង្គជំនុំជម្រះនេះបានសម្រេចដដែលៗថា វិធានទាំងពីរនេះគឺដាច់ពីគ្នា[65] ហើយថា ខ្លួន "រក្សានូវឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការទទួលយកភស្តុតាងថ្មីលើបណ្ដឹងសាទុក្ខ បើទោះជាការរកឃើញផ្ទុយមួយ ឬច្រើន លើប្រភេទវិធានទទួលយកភស្តុតាងសម្រាប់បណ្ដឹងសាទុក្ខ"[66]ក៏ដោយ។ ការតម្រូវនៃវិធាន១០៤(១) និង ១០៨(៧) ទោះជាតាមវិធីណាក៏ដោយ ក៏បានបំពេញដែរ។ ផ្ទុយពីការលើកឡើងដោយឥតប្រយោជន៍របស់សហព្រះ

---

[62] ឯកសារ F28, សំណើ កថាខណ្ឌ ១៤ ។

[63] ឯកសារ F2/3/3/3, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ នួន ជា ទៅនឹងសំណួរនានា ស្ដីពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងឈុតវីដេអូដែលជាកម្មសិទ្ធិរបស់ផលិតករភាពយន្ត Rob Lemkin និង ថេតសម្បត្តិ, ថ្ងៃទី ២៣ កក្កដា ឆ្នាំ ២០១៥, កថាខណ្ឌ ៧។ ឯកសារ F2/7/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំរបស់ នួន ជា សុំឲ្យពិចារណា និងទទួលយកភស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១, ១៣ កក្កដា ឆ្នាំ ២០១៥ កថាខណ្ឌ ៤។

[64] ឯកសារ F28, សំណើ កថាខណ្ឌ ៩។

[65] ឯកសារ F2/5 "សេចក្ដីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្ដឹងសាទុក្ខ" ថ្ងៃទី ២៩ ឧសភា ឆ្នាំ២០១៥ កថាខណ្ឌ ១៥ ដល់ ១៧ (លក្ខណៈវិធាន ១០៤(១) និង ១០៨(៧) តាម "វិធីពីរ" សម្រាប់ការទទួលយកភស្តុតាងសម្រាប់បណ្ដឹងឧទ្ធរណ៍)។

[66] ឯកសារ F2/5 "សេចក្ដីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្ដឹងសាទុក្ខ" ថ្ងៃទី ២៩ ឧសភា ឆ្នាំ២០១៥ជើងទំព័រ ៥១ (ដកស្រង់ សាលក្រម *Lubanga* កថាខណ្ឌ ៦២)

រាជអាជ្ញា[67] តាមពិតនៅក្នុងសំណើ និងបណ្តឹងសាទុក្ខបានរៀបរាប់អំពីអំណះអំណាងជាច្រើនក្នុងការបង្ហាញអំពីសារសំខាន់នៃតម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់ សំ សិទ្ធី សម្រាប់គោលនយោបាយសហឧក្រិដ្ឋកម្មរួម និងអាស្រ័យហេតុនេះហើយសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា[68]។

២៨. ប្រហែលជាទឡ្ហីករណ៍ចម្លែកបំផុតនៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញានោះ គឺថាសំណើធ្វើឡើងមិនទាន់ពេល[69]។ ក្រៅតែពីការយោងទៅដល់ការបញ្ជាក់របស់អង្គជំនុំជម្រះថា "ភាគីត្រូវតែជាទូទៅដាក់សំណើសម្រាប់ភស្តុតាងថ្មី នៅមុនពេលបញ្ចប់សវនាការបណ្តឹងសាទុក្ខ"[70] សហព្រះរាជអាជ្ញា យោងទៅលើសេចក្តីណែនាំអនុវត្តការដាក់ឯកសារ ដែលកំណត់ពេលដប់ថ្ងៃសម្រាប់ការដាក់ចម្លើយតបទៅនឹងសំណើ[71]។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា "នួន ជា ត្រូវការពេលច្រើនជាង៦ដងក្នុងការដាក់សំណើនេះ"[72]។ វាក៏ត្រូវការពេលវេលាប្រហែលជា១២ដងសម្រាប់ចម្ងាយក្នុងការប្រកួតល្បែង cricket។ ភាពពាក់ព័ន្ធគឺអាចប្រៀបធៀបបាន។

## ង. សន្និដ្ឋាន

២៩. សម្រាប់ហេតុផលនេះ មេធាវីការពារក្តី សូមស្នើអង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនៅក្នុងចម្លើយតបទាំងពីរ និងផ្តល់នូវសំណើនៅក្នុងសំណើនេះ។

---

[67] ឯកសារ F28/2 ចម្លើយតបសហព្រះរាជអាជ្ញា កថាខណ្ឌ ៣៦។

[68] ឯកសារ F28/2 ចម្លើយតបសហព្រះរាជអាជ្ញា កថាខណ្ឌ ២៦ ដល់ ៣០។

[69] ឯកសារ F28/2 ចម្លើយតបសហព្រះរាជអាជ្ញា កថាខណ្ឌ ២៩, ៣៣។

[70] ឯកសារ F2/4/3, "សេចក្តីសម្រេចបណ្តោះអាសន្នលើផ្នែកខ្លះនៃសំណើទីមួយរបស់ នួន ជា សុំឲ្យទទួល និង ពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង 00២/0១" 0១ មេសា ឆ្នាំ ២0១៥ កថាខណ្ឌ១៨។

[71] ឯកសារ F28/2 ចម្លើយតបសហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣។

[72] ឯកសារ F28/2 ចម្លើយតបសហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣។

**សហមេធាវីការពារក្ដីលោក នួន ជា**

**សុន អរុណ** Victor KOPPE